# ប្រភេទនៃជំងឺ COVID-19

**ចំណុចសំខាន់ៗ**

- មេរោគប្រភេទថ្មីគឺជាការផ្លាស់ប្តូរនៃទម្រង់មេរោគ។ បច្ចុប្បន្ននេះ មេរោគប្រភេទ Delta គឺជាទម្រង់ទូទៅបំផុតដែលបង្កឱ្យមានជំងឺ COVID-19 នៅសហរដ្ឋអាមេរិក។
- មេរោគប្រភេទ Delta រីករាលដាលងាយស្រួលជាងមេរោគប្រភេទដើមនៃជំងឺ COVID-19។ វាអាចបណ្តាលឱ្យមនុស្សដែលមិនបានចាក់ថ្នាំបង្ការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ។
- ថ្នាំបង្ការជំងឺ COVID-19 មានប្រសិទ្ធិភាពខ្លាំងណាស់ក្នុងការទប់ស្កាត់ការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ និងការស្លាប់ពីការឆ្លងមេរោគប្រភេទ Delta។ ប៉ុន្តែវាពិតជាចាំបាច់ណាស់ដែលអ្នកត្រូវតែបានទទួលការចាក់ថ្នាំបង្ការពេញលេញដើម្បីទទួលបានការការពារ។

## តើអ្វីទៅគឺជាមេរោគប្រភេទថ្មី?

មេរោគជាច្រើនផ្លាស់ប្តូរប្រភេទជាញឹកញាប់តាមរយៈការផ្លាស់ប្តូរទម្រង់។ ការផ្លាស់ប្តូរទម្រង់ទាំងនេះបូកបញ្ចូលគ្នាហើយបង្កើតកំណែប្រែមេរោគខុសគ្នាបន្តិចបន្តួចដែលហៅថា "មេរោគប្រភេទថ្មី"។ ពេលខ្លះមេរោគប្រភេទថ្មីលេចឡើង ហើយបន្ទាប់មកក៏បាត់ទៅវិញ។ ពេលខ្លះទៀតមេរោគប្រភេទថ្មីស្ថិតនៅជាប់។ មេរោគទាំងនេះត្រូវបានគេហៅថា មេរោគប្រភេទថ្មីដែលគួរឱ្យព្រួយបារម្ភ ប្រសិនបើមានភស្តុតាងដែលបង្ហាញថាពួកវារីករាលដាលកាន់តែងាយស្រួល បណ្តាលឱ្យធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរជាងមុន ពិបាកក្នុងការតាមដានរក ការព្យាបាល ឬទប់ស្កាត់ដោយប្រើថ្នាំបង្ការ។ អ្នកវិទ្យាសាស្ត្របន្តសិក្សា និងតាមដានមេរោគប្រភេទថ្មីទាំងនេះនៅពេលពួកវាផ្លាស់ប្តូរខ្លួន។

មេរោគប្រភេទថ្មីនៃជំងឺ COVID-19 ជាច្រើនបានបង្ហាញខ្លួននៅសហរដ្ឋអាមេរិក។ នៅពេលនេះ មេរោគប្រភេទដើមដែលបានរីករាលដាលកាលខែមករា ឆ្នាំ 2020 លែងមានការសាយភាយទៀតហើយ។

## តើប្រភេទមេរោគថ្មីនៃជំងឺ COVID-19 ណាខ្លះដែលត្រូវបានរកឃើញនៅសហរដ្ឋអាមេរិក?

មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (CDC) កំពុងតាមដានមេរោគប្រភេទថ្មីដែលគួរឱ្យព្រួយបារម្ភមួយចំនួននៅសហរដ្ឋអាមេរិក៖

| ឈ្មោះមេរោគប្រភេទថ្មី៖ | បានរកឃើញដំបូង៖ | រកឃើញដំបូងនៅអាមេរិក៖ |
|---|---|---|
| **អាល់ហ្វា (Alpha)** (B.1.1.7) | ចក្រភពអង់គ្លេស | ខែធ្នូ ឆ្នាំ2020 |
| **បេតា (Belta)** (B.1.351) | ប្រទេសអាហ្វ្រិកខាងត្បូង | ខែមករា ឆ្នាំ2021 |
| **ហ្គាម៉ា (Gamma)** (P.1) | តាមអ្នកធ្វើដំណើរពីប្រទេសប្រេស៊ីល | ខែមករា ឆ្នាំ2021 |
| **ដែលតា (Delta)** (B.1.17.2) | ប្រទេសឥណ្ឌា | ខែមីនា ឆ្នាំ2021 |

បច្ចុប្បន្ននេះមេរោគប្រភេទ Delta គឺជាទម្រង់មេរោគដែលកើតឡើងទូទៅបំផុតនៅខោនធី Los Angeles។ សូមចូលទៅកាន់គេហទំព័រ អ្វីដែលអ្នកត្រូវស្វែងយល់អំពីមេរោគប្រភេទថ្មី របស់ CDC សម្រាប់ព័ត៌មានបន្ថែម។

## តើមេរោគប្រភេទថ្មីទាំងនេះមានគ្រោះថ្នាក់ខ្លាំងជាងមុនដែរឬទេ?

វាអាស្រ័យទៅលើមនុស្ស។ មេរោគប្រភេទថ្មីទាំងនេះមួយចំនួនគឺជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ជាពិសេសដល់មនុស្សដែលមិនបានចាក់ថ្នាំបង្ការពេញលេញ[1] និងអ្នកដែល ប្រឈមនឹងហានិភ័យខ្ពស់នៃការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរពីជំងឺ COVID-19។ មេរោគប្រភេទ Delta ជាមេរោគប្រភេទថ្មីដែលកំពុងបង្កការព្រួយបារម្ភ ពីព្រោះវារីករាលដាលងាយស្រួលជាងមេរោគប្រភេទដើម និងមេរោគប្រភេទថ្មីផ្សេងទៀត។ វាក៏អាចបណ្តាលឱ្យអ្នកដែលមិនបានចាក់ថ្នាំបង្ការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរផងដែរ។

## តើថ្នាំបង្ការជំងឺ COVID-19 ការពារប្រឆាំងនឹងមេរោគប្រភេទថ្មី រួមទាំងមេរោគប្រភេទ Delta នេះដែរឬទេ?

បាទ/ចាស ថ្នាំបង្ការទាំងនេះពិតជាអាចការពារបាន។ មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (CDC) និងអ្នកជំនាញផ្សេងទៀតនៅតែបន្តសិក្សាថា តើថ្នាំបង្ការដំណើរការដើម្បីការពារមនុស្សពីជំងឺ COVID-19 បានល្អប៉ុណ្ណា។ CDC បានរកឃើញថាថ្នាំបង្ការទាំង 3 ប្រភេទ ដែលអាចរកបាននៅសហរដ្ឋអាមេរិក មានប្រសិទ្ធភាពខ្ពស់ក្នុងការការពារមនុស្សពីការ

[1] អ្នកត្រូវបានគេចាត់ទុកថា បានចាក់ថ្នាំបង្ការពេញលេញប្រឆាំងនឹងជំងឺ COVID-19 ពីរ (2) សប្តាហ៍បន្ទាប់ពី៖ ការចាក់ដូសទីពីរនៃថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ឬ Moderna និងការចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Johnson & Johnson តែមួយដូស ឬអ្នកបានបញ្ចប់ការចាក់ជាលំដាប់នៃថ្នាំបង្ការជំងឺ COVID-19 ណាដែលត្រូវបានចុះបញ្ជីឱ្យប្រើប្រាស់ជាបន្ទាន់ដោយអង្គការសុខភាពពិភពលោក។ សូមមើលគេហទំព័រ បានចាក់ថ្នាំបង្ការពេញលេញ សម្រាប់ព័ត៌មានបន្ថែម។

# ប្រភេទនៃជំងឺ COVID-19

ធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ និងការស្លាប់ពីមេរោគប្រភេទ Delta ក៏ដូចជាពីមេរោគប្រភេទថ្មីផ្សេងៗទៀតដែលគេបានស្គាល់ផងដែរ។ បុគ្គលដែលបានចាក់ថ្នាំបង្ការពេញលេញក៏មិនទំនងជាអាចឆ្លងមេរោគ COVID-19 បានទេ បើប្រៀបធៀបជាមួយអ្នកដែលមិនបានទទួលការចាក់ថ្នាំបង្ការ។

## តើការឆ្លងមេរោគវាយទម្លុះ (breakthrough infection) គឺជាអ្វី?

ថ្នាំបង្ការជំងឺ COVID-19 កាត់បន្ថយហានិភ័យនៃការឆ្លងមេរោគ COVID-19 ប៉ុន្តែដោយសារថ្នាំបង្ការមិនមានប្រសិទ្ធភាព 100% នោះ មនុស្សមួយចំនួនតូចដែលបានចាក់ថ្នាំបង្ការពេញលេញអាចនឹងឆ្លងជំងឺបានដែរ។ នេះត្រូវបានគេហៅថា "ការឆ្លងមេរោគវាយទម្លុះ"។ ការឆ្លងមេរោគវាយទម្លុះ ជាធម្មតាបណ្តាលឱ្យមានជំងឺស្រាលៗប៉ុណ្ណោះ។ ប្រសិនបើអ្នកបានចាក់ថ្នាំបង្ការពេញលេញ ហានិភ័យរបស់អ្នកក្នុងការឆ្លងជំងឺ ធ្លាក់ខ្លួនឈឺ ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬការស្លាប់ គឺស្ថិតនៅកម្រិតទាបជាង ប្រសិនបើអ្នកមិនបានចាក់ថ្នាំបង្ការ។ មនុស្សមួយចំនួនដែលបានទទួលថ្នាំបង្ការពេញលេញ និងផ្ទុកមេរោគប្រភេទ Delta អាចចម្លងមេរោគនេះទៅកាន់អ្នកដទៃ។ នេះហាក់ដូចជាតែផ្នែកតូចមួយនៃការរីករាលដាលនៃមេរោគប៉ុណ្ណោះ។

## តើខ្ញុំការពារខ្លួនខ្ញុំពីមេរោគប្រភេទថ្មីបានយ៉ាងដូចម្តេច?

- **ទទួលការចាក់ថ្នាំបង្ការ** ប្រសិនបើអ្នកមានអាយុ 12 ឆ្នាំឡើងទៅ (សូមមើលខាងក្រោម)។ ថ្នាំបង្ការជំងឺ COVID-19 ទាំង 3 ប្រភេទដែលដាក់ឱ្យប្រើប្រាស់នៅសហរដ្ឋអាមេរិក ផ្តល់នូវការការពារដ៏ល្អបំផុតប្រឆាំងនឹងមេរោគប្រភេទថ្មីដែលកំពុងរាលដាលនៅទីនេះ។ ប្រសិនបើអ្នកមានការព្រួយបារម្ភ ឬសំណួរអំពីថ្នាំបង្ការជំងឺ COVID-19 សូមពិភាក្សាជាមួយគ្រូពេទ្យរបស់អ្នក។ ប្រសិនបើអ្នកបានចាក់ថ្នាំបង្ការរួចហើយ សូមជម្រុញឱ្យក្រុមគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់អ្នកឱ្យទៅទទួលថ្នាំបង្ការដែរ។ ការចាក់ថ្នាំបង្ការនឹងកាត់បន្ថយការរីករាលដាលនៃមេរោគប្រភេទថ្មី និងកាត់បន្ថយឱកាសនៃមេរោគប្រភេទថ្មីផ្សេងៗទៀត ដែលកាន់តែគ្រោះថ្នាក់ អាចលេចចេញជារូបរាងបាន។
- **សូមពាក់ម៉ាស់។** ម៉ាស់នៅតែជាឧបករណ៍ដ៏មានឥទ្ធិពលដើម្បីការពារខ្លួនអ្នក និងអ្នកដទៃ។ ដោយសារតែមេរោគប្រភេទ Delta រីករាលដាលកាន់តែងាយស្រួល <u>មនុស្សគ្រប់គ្នា</u>ត្រូវឱ្យពាក់ម៉ាស់នៅពេលនៅខាងក្នុងអគារតាមទីសាធារណៈ និងនៅឯព្រឹត្តិការណ៍ធំៗបំផុត (Mega Events) ដែលនៅខាងក្រៅអគារ។ ការពាក់ម៉ាស់របស់អ្នកគួរតែគ្របលើច្រមុះនិងមាត់របស់អ្នកឱ្យបានជិតល្អ ហើយត្រូវបានផលិតឡើងដោយមានយ៉ាងហោចណាស់ពីរស្រទាប់ ដូច្នេះទើបម៉ាស់នេះអាចច្រោះបានល្អ។ ប្រសិនបើអ្នកនៅក្នុងទីកន្លែងមួយដែលអ្នកមានការប៉ះពាល់ ឬទំនាក់ទំនងជិតស្និទ្ធជាមួយមនុស្សផ្សេងទៀតដែលប្រហែលជាមិនបានចាក់ថ្នាំបង្ការពេញលេញ ចូរពិចារណា "ពាក់ម៉ាស់ពីរជាន់" (ពាក់ម៉ាស់ក្រណាត់ពីលើម៉ាស់វះកាត់) ឬប្រើឧបករណ៍ជំនួយការដកដង្ហើមប្រភេទ N95។ វិធីទាំងនេះផ្តល់នូវការការពារខ្ពស់ជាងមុន។ នេះមានសារៈសំខាន់ជាពិសេស ប្រសិនបើអ្នកមិនបានចាក់ថ្នាំបង្ការពេញលេញ ហើយនៅខាងក្នុងអគារ ឬនៅទីតាំងខាងក្រៅដែលមានមនុស្សច្រើនកុះករ។ ការលើកលែងមួយចំនួនត្រូវបានអនុវត្ត - ស្វែងយល់បន្ថែមនៅ ph.lacounty.gov/masks។
- **សូមលាងសម្អាតដៃរបស់អ្នក និង/ឬប្រើទឹកអនាម័យលាងសម្អាតដៃឱ្យបានញឹកញាប់ -** ជាពិសេសបន្ទាប់ពីស្ថិតនៅទីកន្លែងសាធារណៈនានា ដែលមានផ្ទៃត្រូវបានមនុស្សជាច្រើនប៉ះពាល់។

សូមចូលទៅកាន់គេហទំព័រ ជំងឺ COVID-19៖ ការកាត់បន្ថយហានិភ័យ របស់សុខភាពសាធារណៈដើម្បីស្វែងយល់បន្ថែម។

## តើខ្ញុំចាក់ថ្នាំបង្ការជំងឺ COVID-19 ដោយរបៀបណា?

ថ្នាំបង្ការអាចរកបាននៅទូទាំងខោនធី LA និងដោយឥតគិតថ្លៃសម្រាប់មនុស្សគ្រប់គ្នា ដោយមិនគិតពីស្ថានភាពអន្តោ€ប្រវេសន៍ឡើយ។ ទីតាំងចាក់ថ្នាំបង្ការជាច្រើនកន្លែងទទួលភ្ញៀវដោយមិនត្រូវការណាត់ជាមុន ឬអ្នកអាចជ្រើសរើសធ្វើការណាត់ជួបក៏បាន។

- សូមចូលទៅកាន់គេហទំព័រ www.VaccinateLACounty.com ដើម្បីស្វែងរកទីតាំងដែលនៅជិតអ្នក។
- សូមទូរស័ព្ទទៅលេខ **1-833-540-0473** ប្រសិនបើអ្នកត្រូវការជំនួយក្នុងការធ្វើការណាត់ជួប ត្រូវការការដឹកជញ្ជូនទៅទីតាំងចាក់ថ្នាំបង្ការ ឬមិនអាចចេញពីផ្ទះបាន។ បណ្តាញទូរស័ព្ទបើកបម្រើការពីម៉ោង 8:00 ព្រឹកដល់ម៉ោង 8:30 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍។ ព័ត៌មានអាចរកបានជាច្រើនភាសា 24 ម៉ោងក្នុងមួយសប្តាហ៍ ដោយទូរស័ព្ទទៅកាន់លេខ 2-1-1។

**ដើម្បីស្វែងយល់បន្ថែមអំពីប្រភេទមេរោគ COVID-19 ថ្មីផ្សេងៗ សូមចូលទៅកាន់គេហទំព័រ មេរោគប្រភេទថ្មី របស់ CDC។**